# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រធានក្រុមហ៊ុន AEC Consult & Connect នៃប្រទេសថៃ



នៅរសៀលថ្ងៃទី១២ ខែ កញ្ញា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Kesamsant Weerakun** ប្រធានក្រុមនហ៊ុន **AEC AEC Consult & Connect** នៃប្រទេសថៃ និងសហការី ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។

លោក **Kesamsant Weerakun** ប្រធានក្រុមនហ៊ុន **AEC Consult & Connect** នៃប្រទេសថៃ បានបង្ហាញនូវការមើលឃើញពីភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា គួរជាទីទុកចិត្ត ជាពិសេសគឺទីផ្សាររថយន្ត មានភាពរីកលូតលាស់គួរចាប់អារម្មណ៍ ។ ដូច្នេះ ក្នុងជំនួបពិភាក្សាថ្ងៃនេះ ប្រតិភូរបស់លោកចង់ស្វែងយល់ពីទីផ្សាររថយន្តនៅកម្ពុជា ហើយនឹងពិនិត្យលទ្ធភាពបង្កើតរោងចក្រផលិតរថយន្តនៅទីនេះ ។ ក្រៅពីនោះ ក្រុមហ៊ុនរបស់លោកក៏មានបំណងបង្កើតស្ថានីយ៍ចាក់ហ្គាស នៅតាមដងផ្លូវផងដែរ។ ទាក់ទងគម្រោងវិនិយោគនេះ ប្រតិភូក្រុមហ៊ុនថៃ ក៏ចង់បានការណែនាំពី ឯកឧត្តមទេសរដ្ឋមន្ត្រី និងចង់ស្វែងយល់ពីគោលនយោបាយ បែបបទ វិ និតិវិធីវិនិយោគរបស់កម្ពុជាផងដែរ ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានបញ្ជាក់ថាៈទីផ្សាររថយន្តនៅកម្ពុជាបច្ចុប្បន្ន ពិតជាមានការរីកចម្រើនគួរកត់សំគាល់ ដោយសារការអនុវត្តនូវរបបទីផ្សារសេរីនៅកម្ពុជា ហើយ កំរិតជីវភាពរបស់ប្រជាពលរដ្ឋក៏មានភាពប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ឯកឧត្តម បានបន្តថាៈបច្ចុប្បន្ននៅកម្ពុជា មានការនាំចូលរថយន្ត ទាំងថ្មី និងប្រើហើយ មកពីប្រភពច្រើនប្រទេស ដូចជាៈអាល្លឺម៉ង់–ជប៉ុន–អាមេរិក–ចិន–កូរ៉េ–អង់គ្លេស រួមទាំងប្រទេសថៃផងដែរ។ ហើយសព្វថ្ងៃនេះក៏មានរោងចក្រតម្លើងរថយន្តនៅកម្ពុជា ដូចជា : រោងចក្រតម្លើងរថយន្ត HYUNDAI របស់ប្រទេសកូរ៉េ នៅខេត្តកោះកុង និងរោងចក្រ តម្លើងរថយន្ត FORD របស់អាមេរិកនៅខេត្តព្រះសីហនុ ។ ទោះទងគម្រោងវិនិយោគនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើក្រុមហ៊ុនដាក់ពាក្យ ស្នើសុំវិនិយោគ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍ (CDC) ដែលក្រុមប្រឹក្សានេះនឹងពិនិត្យ មើល ហើយវាយតម្លៃថាៈ តើគម្រោងវិនិយោគនេះស្ថិតក្នុងគោលនយោបាយលើកទឹកចិត្តអ្វីខ្លះ ? ដូចជាៈ គោលនយោបាយលើកលែងពន្ធលើការនាំចូលវត្ថុធាតុដើម ពន្ធនាំចូលគ្រឿងសំណង់បម្រើឱ្យអគាររោងចក្រ និងពន្ធអនុគ្រោះអាជីវកម្មជាដើម ។ ម៉្យាងទៀតច្បាប់កម្ពុជា បានអនុញ្ញាតឱ្យអ្នកវិនិយោគបរទេសដាក់ដើមទុនវិនិយោគរបស់ខ្លួន ១០០% និងមិនកំរិតការផ្ទេរប្រាក់ចំណេញទៅក្រៅប្រទេសឡើយ ។ ទាក់ទង និង បំណងបង្កើតស្ថានីយ៍ចាក់ហ្គាសតាមដងផ្លូវ ឯកឧត្តម ទេសរដ្ឋមន្ត្រី សូមស្វាគមន៍ ពីព្រោះជាជម្រើសថ្មីមួយ ក្នុងខណៈដែលតម្លៃប្រេងសាំងលើទីផ្សារកំពុងមានតម្លៃខ្ពស់ ។ ហើយបច្ចុប្បន្ននេះ នៅកម្ពុជា ក៏មានរថយន្តចាក់ ហ្គាស មួយចំនួន ដែរ ។ ប៉ុន្តែ មិនទាន់មានស្ថានីយ៍ចាក់ហ្គាសច្រើនទេ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានជូនពរឱ្យក្រុមហ៊ុនសម្រេចបានតាមគោលដៅ អាជីវកម្មរបស់ខ្លួនជាពិសេសគម្រោងវិនិយោគនៅកម្ពុជា ។

